ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០១០.......សហវ.......

ថ្ងៃសុក្រ ៥ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី២

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសហការជាមួយធនាគារពាណិជ្ជដៃគូ រួមមាន÷ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងធនាគារ កាណាឌីយ៉ា ក.អ ក្នុងការបង្កើតប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយផ្សារភ្ជាប់នឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងបានដាក់ឱ្យដំណើរការប្រើប្រាស់សម្រាប់ក្រសួង ចំនួន ០៣ (បី) រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត ក្រោមឱវាទនៅទូទាំងប្រទេសរួចហើយ ក្នុងជំហានទី១។ ដោយឡែក នៅក្នុងជំហានទី២ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងដាក់ឱ្យដំណើរការដល់ក្រសួង ចំនួន ១០ (ដប់) បន្ថែមទៀត ដោយគិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ។ ដូច្នេះ ដើម្បីឱ្យប្រព័ន្ធទូទាត់អេឡិចត្រូនិកនេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូទាំងពីរ ដូចតទៅ÷

ក. ក្រសួង ចំនួន១០(ដប់) ដែលនឹងត្រូវអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ក្នុងជំហានទី២ រួមមាន ១.ក្រសួងរ៉ែនិងថាមពល, ២.ក្រសួងពាណិជ្ជកម្ម, ៣.ក្រសួងអប់រំ យុវជន និងកីឡា, ៤.ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ៥.ក្រសួងបរិស្ថាន, ៦.ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ៧.ក្រសួងសាធារណការនិងដឹកជញ្ជូន, ៨.ក្រសួងទេសចរណ៍, ៩.ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ១០.ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងមន្ទីរជំនាញរាជធានី ខេត្ត ក្រោមឱវាទនៅទូទាំងប្រទេស។

ខ. បេឡាករ នៃធនាគារពាណិជ្ជដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ឬ ស្កេន QR កូដ ដែលមាននៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS នៅពេលមានអតិថិជនធ្វើការបង់ចំណូលមិនមែនសារពើពន្ធនៅតាមបញ្ជរធនាគារពាណិជ្ជដៃគូ ដោយធនាគារនឹងធ្វើប្រតិបត្តិការតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ជំនួសឱ្យអតិថិជន និងចេញបណ្ណបង់ប្រាក់ជូនអតិថិជន ដើម្បីរក្សាទុកជាឯកសារ។

គ. ការបង់ចំណូលមិនមែនសារពើពន្ធរបស់អតិថិជនតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក អាចប្រព្រឹត្តិទៅដោយប្រើប្រាស់កម្មវិធីទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (NRMIS App) ឬ តាមកម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ។

ឃ. ចំណូលដែលទទួល និងប្រមូលបានតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក នឹងត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅគណនីដែលបានបើកដូចមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នាបំពេញបន្ថែមស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសម្រាប់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) អនុវត្តនៅទូទាំងប្រទេស។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមធនាគារពាណិជ្ជដៃគូ ជ្រាប និងផ្ដល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងចូលរួមផ្ដល់មតិកែលម្អសម្រាប់ការងារអនុវត្តទៅថ្ងៃអនាគត។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- ធនាគារជាតិនៃកម្ពុជា
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ